អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងរង្វង់ពាក្យផ្ទុយ**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

**បុរេគណិត**

រង្វាស់រង្វាល់ (បញ្ញត្តិស្តីពីរង្វាស់រង្វាល់)

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីររបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬ លេងល្បែង។

**(បុរេគណិត)** ប្រាប់ពីបញ្ញត្តិ (ខ្ពស់ និងទាប  ធំ និងតូច វែង និងខ្លី រត់ និងដើរ លូន)។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**រយៈពេល** ៖ ១០ នាទី

**ឧបករណ៍** ៖ ពាក្យផ្ទុយដែលត្រូវប្រើ ក្រណាត់ឆ័ត្រយោងមានទំហំធំ ឬ ខ្សែ។

**ការរៀបចំ** ៖ រៀបចំពាក្យដែលត្រូវប្រើ ខ្សែ ឬ ក្រណាត់ឆ័ត្រយោងដែលមានទំហំធំតាមចំនួនសិស្ស ។

**សេចក្តីណែនាំ៖**

1. និយាយថា៖ ថ្ងៃនេះអ្នកគ្រូ ឬ លោកគ្រូនឹងលេង **ល្បែងរង្វង់ពាក្យផ្ទុយ** ជាមួយកូនៗទាំងអស់គ្នា។
2. ត្រូវចែកសិស្សជាក្រុម ពី១០ ទៅ ១៥ នាក់ក្នុងមួយក្រុម។
3. បើកន្លែងមានទំហំតូច ក្មេងៗទាំងអស់អាចលេងម្តងមួយក្រុម។
4. ឱ្យក្មេងៗឈរជារង្វង់ តម្រង់ខ្លួនឱ្យត្រង់ មានគម្លាតអាចលាតសន្ធឹងដៃបាន។



5. ចាប់ផ្តើមលោកគ្រូ អ្នកគ្រូឈរនៅពីខាងមុខ ហើយនិយាយពាក្យខ្ពស់ ឬ ទាប វែង ឬ ខ្លី នឹងធ្វើកាយវិការបង្ហាញផង។
6. ឧទាហរណ៍៖និយាយពាក្យថា ខ្ពស់លើកដៃឡើងលើ ហើយឈរចង្អើតដោយចុងជើង។ ចំណែកពាក្យថា ទាបត្រូវអង្គុយចុះ។
7. បន្ទាប់មកចាប់ផ្តើមលេង ឱ្យក្មេងៗចាប់ផ្តើមធ្វើកាយវិការតាមសកម្មភាពដែលបានបង្ហាញ។





**ចំណុចនេះគឺការប្រើខ្សែ ឬ ក្រណាត់ឆ័ត្រយោងសម្រាប់លេង**

8. ការលេងល្បែងនេះដោយប្រើខ្សែ ឬ ក្រណាត់ឆ័ត្រយោង។ ត្រូវឱ្យខ្សែ ឬ ក្រណាត់ឆ័ត្រយោងទៅកាន់ក្មេងៗតាមក្រុម ពេលខ្លះអាចលេងជាក្រុមធំក៏បានតាមស្ថានភាពចំនួនក្មេងជាក់ស្តែង។
9. ឱ្យក្មេងៗកាន់ខ្សែ ឬ ក្រណាត់ឆ័ត្រយោងលាតសន្ធឹងជារង្វង់ទៅតាមចំនួនរបស់ក្មេងៗ និងរង្វង់របស់ក្រណាត់ឆ័ត្រយោង។
10. បន្ទាប់មកលោកគ្រូ អ្នកគ្រូឈរនៅពីខាងមុខ និយាយពាក្យខ្ពស់ ទាប វែង ឬ ខ្លីធ្វើកាយវិការបង្ហាញ។ ឧទាហរណ៍៖និយាយពាក្យថា ខ្ពស់លើកខ្សែ ឬ ក្រណាត់ឆ័ត្រយោងឡើងលើ ហើយឈរចង្អើតដោយចុងជើងឱ្យខ្ពស់។ ចំណែកពាក្យថា ទាបត្រូវអង្គុយចុះទម្លាក់ខ្សែ ឬ ក្រណាត់ឆ័ត្រយោងចុះដោយកាន់ឱ្យជាប់។





**ការប្រែប្រួល៖**

ប្រសិនបើ មានក្មេងណាម្នាក់ដែលធ្វើសកម្មភាពបានល្អ សុំឱ្យក្មេងនោះធ្វើជាអ្នកស្រែកពាក្យផ្ទុយម្តង។